**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទេរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ១៩៥ សជណ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ២៤៧ លស ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៩៤៥៣ សហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតលេខ ១០០៣ សជណ.ផក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១២៦៥ លស ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ៩៤៥២ សហវ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- លិខិតលេខ ៧២ សជណ.ផអ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ០៨០៤ ផក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងផែនការ
- លិខិតលេខ ៩៤៥៤ សហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតលេខ ១៣៦ សជណ.អវ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៨៩/១៩ ក.ធ.ស.ខ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងធម្មការ និងសាសនា
- លិខិតលេខ ៩៤៥៥ សហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតលេខ ៣៥៥ សជណ.សស ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១២៨១ កកន ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងកិច្ចការនារី
- លិខិតលេខ ៩៤៥៦ សហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លិខិតលេខ ៨៩ សជណ.កធ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤៥៨៣ កសក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ ៩៤៥៧ សហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដូចខាងក្រោម÷

- ទីតាំងអតីតចំណតរថយន្ត ១៣មករា ខេត្តបាត់ដំបង ដែលមានដីទំហំ ៤ ៦១៣ ម៉ែត្រក្រឡា ស្ថិតនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង។
- ទីតាំងដីកសិកម្មបឹងត្នោត ខេត្តកណ្ដាល ដែលមានទំហំ ៨៣៥ ៩៩៣ ម៉ែត្រក្រឡា ស្ថិតនៅភូមិសត្យ ស្រុកស្អាង ខេត្តកណ្ដាល ។
- ទីតាំងមន្ទីរផែនការ ខេត្តព្រះសីហនុ ដែលមានដីទំហំ ២ ៧០០ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវ ២៨មិថុនា ភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។
- ទីតាំងមន្ទីរធម្មការ និងសាសនា ខេត្តព្រះសីហនុ ដែលមានដីទំហំ ២ ៥០៦ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវ ២៨មិថុនា ភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។
- ទីតាំងមន្ទីរកិច្ចការនារី ខេត្តព្រះសីហនុ ដែលមានដីទំហំ ៣ ១៦៨ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវ ២៨មិថុនា ភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងមជ្ឈមណ្ឌលស្ត្រី មានដីទំហំ ២ ០១២ ម៉ែត្រក្រឡា ។
- ទីតាំងអធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រខេត្តព្រះសីហនុ ដែលមានដីទំហំ ៣ ៥៤៦ ម៉ែត្រក្រឡា ស្ថិតនៅផ្លូវ ២៨មិថុនា ភូមិ១ សង្កាត់លេខ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**មាត្រា២.-**

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតនៅក្រោមការចាត់ចែងតាមបែបបទ និងនីតិវិធីជាធរមាន ដោយក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងធម្មការ និងសាសនា ក្រសួងកិច្ចការនារី និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ជាទុកជានិរាករណ៍។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ១០ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ